# ទន្សាយក្រៅចន្ទ្រ

ទន្សាយពេលរស់សម្លឹងចន្ទ្រ
ហ៊ានប្តូរជីវិតស្លាប់មិនស្តាយ
ពុំប្រាថ្នាចន្ទ្រលំអានខ្លួន
ពីចម្ងាយក៏អស់ចិត្តដែរ
ទោះថ្ងៃពេញបោរមិនឋិតថេរ
នៅទន្ទឹងចន្ទ្រឥតឡើយណាយ
ក្រោយស្លាប់ទន្សាយមិនប៉ងអ្វី
ពីចន្ទ្រសូមតែឱយនៅឋិត
ស្រាប់តែក្ស័យហើយចន្ទ្រភ្លេចអស់
ទន្សាយចោលឆ្អឹងជាប់ឈើចាប់
ចង់រស់រួមទុក្ខនឹងចន្ទ្រា
ផែនដីចាកហើយចន្ទ្រពន្លក
ទន្សាយក្នុងខែប្រែក្រៅចន្ទ្រ
ចន្ទ្រាភ្លឺថ្លាមិនប្រាកដ

ទុកខែសំខាន់ស្មើរូបកាយ
ពេលរស់ឃ្លាតឆ្ងាយស្លាប់សូមក្បែរ។
មើលចន្ទ្រសមសួនក៏បានល្ហែ
នេះហើយជាស្នេហាពីទីឆ្ងាយ។
អ្វីដែលមិនអេគឺទន្សាយ
មិនអាចក្បែរកាយអាចក្បែរចិត្ត។
ក្រៅពីសុំក្តីសន្តោសពិត
អស់មួយជីវិតនៃក្តីស្លាប់។
មិនមានស្រណោះចន្ទ្រក្រលាប់
គ្មានទីសម្រាប់ទន្សោយជ្រក។
សូន្យទាំងទីផ្កាផ្លាប់ទៅមក
មិនទទួលយកសែនកំសត់។
សូន្យវិញ្ញាណក្ខន្ធចាំចិត្តក្បួង
ទន្សាយសូមស្បថនៅក្រៅចន្ទ្រ។

ដោយ តៃ សុវណ្ណារុណ

សុក្រ, ១២:២៣-១២:៤៦, ០១/០២/២០១៣